# ស្ថានទូតអូស្ត្រាលី ភ្នំពេញ

## <u>សេចក្ដីប្រកាសព័ត៌មាន</u>

ថ្ងៃទី ៧ ខែ តុលា ឆ្នាំ២០២០

## ជួយកម្ពុជាប្រយុទ្ធប្រឆាំងឱសថក្លែងក្លាយ

រដ្ឋាភិបាលអូស្ត្រាលីមានសេចក្ដីសោមនស្សរីករាយក្នុងការផ្ដល់ជំនួយចំនួន ១លាន ដុល្លាអូស្ត្រាលីដើម្បីពង្រឹងមន្ទីរពិសោធន៍ជាតិត្រួតពិនិត្យឱសថរបស់កម្ពុជា និងសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ។ ជំនួយនេះនឹងត្រូវផ្ដល់ តាមរយៈអង្គការក្រៅរដ្ឋាភិបាលជំនាញដែលមានឈ្មោះថា United States Pharmacopeia សម្រាប់រយៈពេល ២ឆ្នាំ (២០២០-២០២២)។

ជំនួយរបស់ប្រទេសអូស្ត្រាលី នឹងជួយមន្ទីរពិសោធន៍ជាតិគ្រប់គ្រងគុណភាព នៃផលិតផលវេជ្ជសាស្ត្រ របស់កម្ពុជា លើកកំពស់ប្រព័ន្ធគ្រប់គ្រងគុណភាពរបស់កម្ពុជា យុទ្ធសាស្ត្រនិងផែនការប្រតិបត្តិការមន្ទីរពិសោធន៍ជាតិ ព្រមទាំងបង្កើនការធ្វើតេស្ត និងរាយការណ៍ អំពីផលិតផលវេជ្ជសាស្ត្រក្លែងក្លាយ និងអន់គុណភាព។

ឯកឧត្តម Pablo Kang ឯកអគ្គរាជទូតអូស្ត្រាលីប្រចាំកម្ពុជា បានមានប្រសាសន៍ថា " មន្ទីរពិសោធន៍ជាតិគ្រប់គ្រងគុណភាព មានសារៈសំខាន់ក្នុងការការពារ ប្រឆាំងនឹងផលិតផលវេជ្ជសាស្ត្រក្លែងក្លាយ និងអន់គុណភាព។ ហេតុនេះហើយ អូស្ត្រាលីមានមោទនភាព ក្នុងការជួយឧបត្ថម្ភ មន្ទីរពិសោធន៍ជាតិគ្រប់គ្រងគុណភាពផលិតផលវេជ្ជសាស្ត្រ របស់កម្ពុជា ដើម្បីត្រៀមលក្ខណៈទទួលបានការទទួលស្គាល់គុណភាពពីអង្គការសុខភាពពិភពលោក។"

អូស្ត្រាលី គឺជាអ្នកគាំទ្រដ៏ធំមួយ ចំពោះប្រព័ន្ធតាមដាន និង ត្រួតពិនិត្យជាសកលរបស់អង្គការសុខភាពពិភពលោក ធ្វើការដើម្បីលើកកំពស់បរិមាណ គុណភាព និងការវិភាគទិន្នន័យត្រឹមត្រូវទាក់ទងនឹងផលិតផលវេជ្ជសាស្ត្រក្លែងក្លាយ និងអន់គុណភាព និងដើម្បីប្រើប្រាស់ទិន្នន័យទាំង

នេះ ក្នុងធ្វើឲ្យប្រសើរឡើងនៃការបង្ការ ការរកឃើញ និងការឆ្លើយតប ដើម្បីការពារសុខភាពសាធារណៈ។ ប្រព័ន្ធតាមដាន និង ត្រួតពិនិត្យជាសកល របស់អង្គការសុខភាពពិភពលោក កំពុងតែជួយបង្កើតការមើលឃើញ ឲ្យកាន់តែច្បាស់នូវប្រភេទ និងកំរិតនៃផលិតផលវេជ្ជសាស្ត្រក្លែងក្លាយ និងអន់គុណភាព ក្នុងខណៈដែលករណីខ្លះកើនឡើងដល់ចំនួនលានករណី។

របាយការណ៍ ឆ្នាំ២០១៧ នៃប្រព័ន្ធតាមដាននិង ត្រួតពិនិត្យជាសកលរបស់អង្គការសុខភាពពិភពលោក បានដកស្រង់ការសិក្សាស្រាវជ្រាវ ដោយបង្ហាញនូវអត្រាបរាជ័យ នៃផលិតផលវេជ្ជសាស្ត្រក្លែងក្លាយ និងអន់គុណភាព ដែលត្រូវគេអង្កេតឃើញនៅក្នុងប្រទេសមានចំណូលទាប និងមធ្យម មានចំនួនប្រហែល ១០ភាគរយ៖ នោះមានន័យថា ក្នុងចំណោមអ្នកប្រើប្រាស់១០នាក់ អាចមាន១នាក់ ដែលជួបប្រទះឱសថប្រឆាំងមេរោគ ឱសថគ្រុនចាញ់ មហារីក និងឱសថផ្សេងៗ ដែលក្លែងក្លាយ។ ការធ្វើឲ្យបទបញ្ញត្តិ កាន់តែមានប្រសិទ្ធិភាព គឺមានសារៈសំខាន់ ក្នុងការធានានូវការទទួលបានឱសថ និងវ៉ាក់សាំងដែលមានសុវត្ថិភាព ប្រសិទ្ធិភាព និងគុណភាព។

ជំនួយថ្មីៗ ចុងក្រោយរបស់អូស្ត្រាលីចំពោះកម្ពុជា គឺបន្ថែមទៅលើជំនួយ ៥០លានដុល្លាអូស្ត្រាលី ដែលយើងកំពុងគាំទ្រដល់គម្រោងលើកកំពស់សមធម៌ និងគុណភាពសុខាភិបាល (H-EQIP)។

ទំនាក់ទំនងព័ត៌មាន៖ Australian.Embassy.Cambodia@dfat.gov.au




រូបថត៖ ពីឆ្វេងទៅស្តាំ

១. លោកវេជ្ជបណ្ឌិត ទេព គីឡា នាយកមជ្ឈមណ្ឌលជាតិពិសោធន៍សុខាភិបាល

២. លោកវេជ្ជបណ្ឌិត អ៊ុយ សុខចំរើន អនុប្រធានការិយាល័យបច្ចេកទេស ទទួលបន្ទុកមន្ទីរពិសោធន៍រូបគីមីសាស្ត្រ

៣. លោកវេជ្ជបណ្ឌិត Robin Davies ប្រធានមជ្ឍមណ្ឌលឥណ្ឌាប៉ាស៊ីហ្វិកសម្រាប់សន្តិសុខសុខាភិបាល

៤. លោកស្រីវេជ្ជបណ្ឌិត Prudence Borthwick ប្រធានជំនួយមជ្ឍមណ្ឌលឥណ្ឌាប៉ាស៊ីហ្វិកសម្រាប់សន្តិសុខសុខាភិបាល

៥. លោកវេជ្ជបណ្ឌិត តី សុវណ្ណារិទ្ធ នាយករងនៃមជ្ឈមណ្ឌលជាតិពិសោធន៍សុខាភិបាល ទទួលបន្ទុកធានាគុណភាព